# សេចក្តីថ្លែងការណ៍រួម

## ភ្នំពេញ ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០២៦

សហជីពជាសមាជិកសហជីពសកល IndustriALL នៅកម្ពុជា និងសហជីពសកល IndustriALL ស្វាគមន៍អនុសាសន៍ពីដៃគូខាងក្រៅ ពាក់ព័ន្ធនឹងមាតិការ និងដំណើរការនៃអនុសញ្ញារួម (CBAs) ដែលត្រូវបានអនុវត្តដោយមានការគាំទ្រពីបណ្ដាក្រុមហ៊ុនម្ចាស់ម៉ាក និងក្រុមហ៊ុនលក់រាយអន្តរជាតិនៅក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា។ ការគាំទ្រ និងមាតិកានៃអនុសញ្ញារួមទាំងនេះ បានបង្ហាញពីការចរចាជាច្រើនឆ្នាំរវាងសហព័ន្ធសហជីពកម្ពុជា សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា (TAFTAC) សហជីពសកល IndustriALL និងបណ្ដាក្រុមហ៊ុនម្ចាស់ម៉ាកនានា។

កម្មវិធីរបស់យើងត្រូវបានរៀបចំឡើង ដើម្បីផ្តល់លទ្ធភាពឱ្យធ្វើការកែលម្អជាបន្តបន្ទាប់លើប្រាក់ឈ្នួល និងលក្ខខណ្ឌការងារ ហើយអនុសញ្ញារួមដែលគាំទ្រដោយក្រុមហ៊ុនម្ចាស់ម៉ាកទាំងនេះ បានផ្តល់នូវវិធីសាស្ត្រមួយជាលើកដំបូងក្នុងការសម្រេចបានការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ ដោយមានការគាំទ្រយ៉ាងពិតប្រាកដពីក្រុមហ៊ុនម្ចាស់ម៉ាក។

នេះជាកម្មវិធីដំបូងបំផុតនៅក្នុងឧស្សាហកម្មកាត់ដេរពិភពលោក ដែលក្រុមហ៊ុនម្ចាស់ម៉ាកនានាត្រូវបានបញ្ចូលទៅក្នុងរចនាសម្ព័ន្ធគាំទ្រប្រាក់ឈ្នួល ដែលមានលក្ខណៈចងកាតព្វកិច្ចផ្លូវច្បាប់។ ក្នុងនាមជាតំណាងកម្មករនិយោជិត យើងខ្ញុំផ្តោតការយកចិត្តទុកដាក់ទៅលើការបន្តពង្រីកវិធីសាស្ត្រខ្សែសង្វាក់ផ្គត់ផ្គង់ ដើម្បីផ្តល់នូវការដំឡើងប្រាក់ឈ្នួលដល់កម្មករនិយោជិត នៅពេលដែលវិធីសាស្ត្របែបស្ម័គ្រចិត្តផ្សេងៗទៀត នៅតែមិនអាចសម្រេចបានលទ្ធផលសំខាន់នៅឡើយ។

យើងខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះចេតនាកែលម្អ និងបង្កើនលទ្ធផលនៃអនុសញ្ញារួម ដែលគាំទ្រដោយក្រុមហ៊ុនម្ចាស់ម៉ាកទាំងនេះ។ យើងខ្ញុំនឹងបន្តប្រើប្រាស់វេទិកាដែលមានក្រុមហ៊ុនម្ចាស់ម៉ាក និងនិយោជក ក្រោមការគាំទ្រដោយ ACT ជាមធ្យោបាយក្នុងការដោះស្រាយបញ្ហាប្រឈមនានា និងពង្រីកវិសាលភាពនៃអនុសញ្ញារួម។ កម្មវិធីរបស់យើងអាចសម្រេចសក្តានុពលពេញលេញទៅបាន លុះត្រាតែមានការគាំទ្រពីក្រុមហ៊ុនម្ចាស់ម៉ាកកាន់តែច្រើនថែមទៀត។ យើងខ្ញុំជំរុញឱ្យក្រុមហ៊ុនម្ចាស់ម៉ាកទាំងអស់ដែលបញ្ជាទិញពីប្រទេសកម្ពុជា មកចូលរួមជាមួយយើងខ្ញុំ និងធ្វើការប្តេជ្ញាច្បាស់លាស់ក្នុងការគាំទ្រដល់ការដំឡើងប្រាក់ឈ្នួលដែលបានចរចាសម្រាប់កម្មករនិយោជិតនៅកម្ពុជា។

# Joint Statement

## Phnom Penh, 2 July, 2026

IndustriALL affiliated trade unions in Cambodia and IndustriALL Global Union welcome recommendations from external partners on the content and process of the collective bargaining agreements implemented with the support from a group of international brands and retailers in the Cambodia industry. The support for and content of the CBAs reflects years of negotiation between Cambodian Trade Union Federations, TAFTAC, IndustriALL Global Union and a group of brands.

Our programme is set up to allow for continuous improvements in wages and working conditions, and the brand-supported CBAs provide, for the first time, a pathway towards improved conditions supported by tangible contributions from brands.

The programme is the first time in the global garment industry that brands are included in a binding wage support structure. As worker representatives, we are focused on further expanding supply chain approaches that provide wage increases to workers while other voluntary approaches continue to fail to deliver.

We appreciate the intention to improve and extend the impact of the brand-supported CBAs. We will continue to use the platform with brands and employers supported through ACT as a vehicle to address challenges and expand the coverage of CBAs. Our programme can only achieve its full potential through the support of a growing number of brands. We urge all brands sourcing from Cambodia to engage with us and make substantial commitments in support of negotiated wage increases for Cambodian workers.